អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C

**សកម្មភាព** ៖ **ល្បែងគ្រប់យ៉ាងអំពីសត្វខូអាឡា**

**វិទ្យាសាស្ត្រ**

ការរស់នៅប្រចាំថ្ងៃ (ការស្វែងយល់ដោយការសង្កេត)

**សិក្សាសង្គម**

ចម្រៀង និងតន្ត្រី (ចំណេះដឹងបច្ចេកទេសការច្នៃប្រឌិត និងបទពិសោធតន្ត្រី)

**គោលបំណង** ៖

**(វិទ្យាសាស្ត)** ប្រាប់បានពីឈ្មោះសត្វផ្សេងៗ រៀបរាប់ឈ្មោះសត្វ ចរិកលក្ខណៈ លក្ខខណ្ឌរស់នៅ វដ្តនៃសត្វ ការប្រៀបធៀបនៃសត្វ និងផលប្រយោជន៍។

**(សិក្សាសង្គម)** ច្រៀងចំរៀង និងធ្វើកាយវិការតាមខ្លឹមផ្សារបទចម្រៀងបាន១បទឬលើសពីនេះ។

**រយៈពេល** ៖ ៣០ នាទី

**ឧបករណ៍** ៖

-ក្រដាសពណណ៌នាពីរឿងពិតរបស់សត្វខូអាឡា

-បទចម្រៀងសត្វខូអាឡា

**ការរៀបចំ** ៖ ផែនទីពិភពលោក បង្ហាញប្រទេសអូស្ដាលី បោះពុម្ភចេញរូបភាពសត្វខូអាឡាពិតប្រាកដ និងបង្ហាញផ្នែកខ្លះនៃរាង្គកាយ។

**សេចក្តីណែនាំ៖**

1. និយាយថា៖ ថ្ងៃនេះអ្នកគ្រូនឹងពិពណ៌នារឿងពិតរបស់សត្វខូអាឡាឱ្យកូនៗស្តាប់។
2. ត្រូវពិពណ៌នាអំពីសត្វខូអាឡា និងបង្ហាញរូបភាព “សត្វខូអាឡា” ។
   -ក្រដាសពិពណ៌នាពីរឿងពិតរបស់សត្វខូអាឡា
3. សួរក្មេងៗថា៖ តើកូនៗស្គាល់សត្វខូអាឡាដែរឬទេ?
4. និយាយពាក្យថា៖ “សត្វខូអាឡា” ទៅកាន់ក្មេងៗ រួចឱ្យក្មេងៗថាតាម។
5. សួរសំណួរក្មេងៗ៖ តើសត្វខូអាឡាមាននៅប្រទេសណា?
   មាននៅតែ” ប្រទេសអូស្ត្រាលី” តែប៉ុណ្ណោះ។
6. បង្ហាញក្មេងៗពីផែនទីពិភពលោក និង**ប្រទេសអូស្ត្រាលី**ឱ្យក្មេងៗនិយាយតាម។

7. ចង្អុលនិងប្រាប់ឈ្មោះផ្នែករាង្គកាយនីមួយៗរបស់សត្វខូអាឡានិងឱ្យក្មេងៗថាតាម។
8. សួរក្មេងៗបន្តថា៖ តើមានសត្វអ្វីផ្សេងទៀតដែលមានរាងកាយដូចនឹងសត្វខូអាឡាដែរឬទេ? ដំរី ខ្លាឃ្មុំ…ជាដើម។
9. សួរក្មេងៗថា៖ តើសត្វខូអាឡាជាប្រភេទអ្វី? សត្វខូអាឡាជាសត្វប្រភេទថនិក។
10. តើសត្វខូអាឡាចិញ្ចឹមកូនដោយរបៀបណា? គឺសត្វចិញ្ចឹមកូនដោយទឹកដោះ។
11. តើសត្វខូអាឡារកចំណីអាហារនៅពេលណា? សត្វខូអាឡាជាសត្វរាត្រីចរ គឺយប់ទើបរកចំណី។
12. តើសត្វខូអាឡា ស៊ីចំណីអ្វីខ្លះជាអាហារ? ស៊ីតែស្លឹកឈើ(ដើមប្រេងខ្យល់) តែប៉ុណ្ណោះ។
13. សួរក្មេងៗថា៖ ប្រសិនបើកូនៗអាចញ៉ាំអាហារបានតែ២មុខ តើកូនៗនឹងជ្រើសរើសមុខម្ហូបអ្វីខ្លះ?
14. ច្រៀងបទចម្រៀង សត្វខូអាឡា និងបង្ហាញកាយវិការ និងឱ្យក្មេងៗរៀនច្រៀងតាម។

**ការប្រែប្រួល**

លេងសកម្មភាពនេះជាមួយនឹងប្រភេទសត្វផ្សេងទៀត ដូចជា៖ សត្វដំរីនិងអាចប្រើបទចម្រៀងសត្វដំរីបាន។ (បទចម្រៀង សត្វដំរី)